CAMBODIA CLIMATE CHANGE ALLIANCE

Implemented by: Ministry of Environment — Supported by: European Union, UNDP, SWEDEN

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## ការប្រកាសចាប់ផ្តើមផ្តល់ជំនួយឥតសំណងដល់គម្រោងស្រាវជ្រាវ និងការច្នៃប្រឌិត ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

ភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ - អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានទីតាំងនៅក្នុងក្រសួងបរិស្ថានបាន **ប្រកាសចាប់ផ្តើមផ្តល់ជំនួយឥតសំណងដល់គម្រោងស្រាវជ្រាវ និងការច្នៃប្រឌិត** ក្នុងការគាំទ្រសកម្មភាពអាទិភាពជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (កម្មវិធី CCCA)។ គម្រោងសរុបចំនួន ប្រាំពីរ ទៅ ដប់ នឹងរំពឹងថាទទួលជំនួយឥតសំណង ដែលមួយគម្រោងថវិកាចាប់ពី ៥០.០០០ រហូតដល់ ១០០.០០០ដុល្លាអាមេរិក។ សិក្ខាសាលានេះចូលរួមដោយតំណាងស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានសិក្សា និងអង្គការមិនមែនរដ្ឋាភិបាល សរុបជាង១២០នាក់។

នៅក្នុងពិធីប្រកាសចាប់ផ្តើម លោក **ស៊ុំ ធី** ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន និងជាប្រធានគ្រប់គ្រងនៃកម្មវិធី CCCA បានបញ្ជាក់អំពីសារៈសំខាន់នៃការពង្រឹងធនធានមនុស្ស និងអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់គោលបំណងអភិវឌ្ឍន៍ដោយចីរភាពថា *"ការពង្រឹងសមត្ថភាពមនុស្ស និងបច្ចេកទេស គឺជាផ្នែកមួយក្នុងចំណោមផ្នែកសំខាន់របស់កម្មវិធី CCCA ដើម្បីគាំទ្រការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ហេតុនេះ កម្មវិធី CCCA ដែលទទួលពហុជំនួយពីសហភាពអឺរ៉ុប (EU) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ (SIDA) បានឯកភាពរួមគ្នាវិភាជមូលនិធិទៅកាន់ស្ថាប័នដែលមានសមត្ថភាពស្វែងរកបច្ចេកវិទ្យា និងវិធីសាស្រ្តច្នៃប្រឌិតថ្មីៗឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយរួមបញ្ចូលទាំងការស្រាវជ្រាវ"*។

ចំនុចផ្តោតនៃមូលនិធិស្រាវជ្រាវ និងការច្នៃប្រឌិត រួមមាន ១) ការងារបន្សាំ ២) ការកាត់បន្ថយ និងសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ៣) ការងារបន្សាំ និងកាត់បន្ថយ។ ការស្រាវជ្រាវ និងច្នៃប្រឌិត គឺជាចំនុចសំខាន់នៃសំណើគម្រោង (មិនមែនជាគម្រោង "តាមទម្លាប់ធម្មតា") ដែលត្រូវបញ្ជាក់ច្បាស់អំពីគុណតម្លៃបន្ថែមទៅលើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ សកម្មភាពដែលស្នើឡើង ត្រូវបង្ហាញអំពីសក្តានុពលដែលត្រូវអនុវត្តសម្រាប់ជាកាតាលីករកៀរគរប្រភពហិរញ្ញប្បទានកាបូន។

ស្ថាប័នដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការដាក់សំណើរ រួមមាន ១) ក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាលដែលបានអនុម័តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឬនាយកដ្ឋាន/វិទ្យាស្ថាននៃស្ថាប័ននោះ ២) អង្គការមិនមែនរដ្ឋាភិបាល (អង្គការក្នុងស្រុក ឬអន្តរជាតិដែលមានមូលដ្ឋានក្នុងប្រទេសកម្ពុជា) និង ៣) សាកលវិទ្យាល័យ ឬវិទ្យាស្ថានស្រាវជ្រាវ (មានមូលដ្ឋានក្នុងប្រទេសកម្ពុជា)។

ព័ត៌មានលម្អិត និងតម្រូវការផ្សេងៗនៃការរៀបចំសំណើរគម្រោង មានចែងនៅក្នុងគោលការណ៍ណែនាំរៀបចំសំណើរគម្រោង ដែលអាចទាញយកពីគេហទំព័រនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន http://www.camclimate.org.kh/en/documents-and-media/library/category/134-window-3-research-and-innovation-projects.html។

ស្ថាប័នដែលចាប់អារម្មណ៍ ត្រូវបញ្ជូនសំណើរគម្រោងខ្លី និងឯកសារភ្ជាប់ទាំងអស់ ជាឯកសាររឹង (១ច្បាប់) និងឯកសារទន់ (តាមរយៈ USB ឬ CD) មកនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៅអគារលេខ១១១ វិធីសុធារស រាជធានីភ្នំពេញ ត្រឹមថ្ងៃ**សុក្រ ទី៣០ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោង ១៧:០០**។

សម្រាប់ព័ត៌មានបន្ថែមអំពីការរៀបចំសំណើគម្រោង សូមទាក់ទង secretariat@camclimate.org.kh។

CAMBODIA CLIMATE CHANGE ALLIANCE

# Press Release

## Launching a Call for Proposals on Research and Innovation Grants Responding to Climate Change

Phnom Penh, 15 September 2015, The General Secretariat for Sustainable Development (GSSD), hosted by the Ministry of Environment launched a **Call for Proposals on Research and Innovation Grants** in support of the national climate change priorities, with support from the Cambodia Climate Change Alliance programme (CCCA). Seven to ten grants are expected to be awarded, with an individual amount between USD 50,000 and USD 100,000. The workshop was attended by over 120 participants, from Government, academia and NGOs.

**Mr. Sum Thy**, Director of the Climate Change Department and CCCA Programme Manager, mentioned the importance of human resource strengthening and technological development for Cambodia's sustainable development objectives. "Strengthening of human and technical capacities is one of the CCCA's key results to support the climate change response. Therefore, EU, UNDP and Sweden have agreed to allocate funds to support qualified organizations to explore new innovations in climate change technologies and approaches, including research".

The focus areas for research and innovation grants cover adaptation, greenhouse gas (GHG) mitigation and inventory, and activities related to both adaptation and mitigation. Research and innovation must be at the core of the proposal (no "business-as-usual"), clearly explain how it will add value to the climate change response in Cambodia, and its concrete implications for climate change policies and/or programming. The proposed activities, additionally, must demonstrate potential to act as catalysts for the mobilization of other sources of climate finance.

Eligible entities include 1) Government ministries or agencies with an approved Climate Change Action Plan (CCAP), or their departments/institutes; 2) Non-governmental organizations (local and international based in Cambodia); and 3) Universities and research centers (based in Cambodia).

Details on specific focus areas for this call and other application requirements are listed in the **Grant Application Guidelines**, which can be downloaded from http://www.camclimate.org.kh/en/documents-and-media/library/category/134-window-3-research-and-innovation-projects.html .

Applicants must submit a concept note and all required documents in hard copy (1 set) and soft copy (on USB stick) to the GSSD- Climate Change Department, #111 Sothearos Bld., Phnom Penh, **not later than Friday 30 October 2015, 17:00.**

For specific query on the proposals, please kindly contact secretariat@camclimate.org.kh.